បានធ្វើបច្ចុប្បន្នភាព៖ 08/16/2024

# ការប្រើប្រាស់ Explore

School District of Philadelphia បានចាប់ផ្តើមបើកដំណើរការឧបករណ៍ថ្មីមួយដែលមានឈ្មោះថា Explore។ Explore ជួយមាតាបិតា និងអាណាព្យាបាលកំណត់អត្តសញ្ញាណសាលារៀនប្រចាំតំបន់ចំណុះរបស់កូនពួកគេ ដែលជាសាលាដែលកុមារនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ ដោយផ្អែកលើលំនៅឋានចម្បងរបស់កុមារ។ Explore ក៏អាចត្រូវបានប្រើដើម្បីស្វែងយល់បន្ថែមអំពីសាលានៅ School District of Philadelphia លើសពីសាលារបស់សិស្ស ដែលអាចគាំទ្រគ្រួសារដែលចាប់អារម្មណ៍លើការចូលរួមក្នុងដំណើរការជ្រើសរើសសាលារៀនរបស់ School District of Philadelphia។

ឧបករណ៍ Explore រួមមានមុខងារអន្តរកម្ម និងងាយស្រួលប្រើជាច្រើន ដែលត្រូវបានបង្កើតឡើងដើម្បីជួយមាតាបិតា និងអាណាព្យាបាលឱ្យទទួលបានព័ត៌មានសំខាន់ៗអំពីសាលានៅ School District of Philadelphia។

ដើម្បីចូលប្រើ **Explore** សូមចូលទៅកាន់គេហទំព័ររបស់ School District of Philadelphia(www.philasd.org)។ ចុច ***Schools (សាលា)*** ក្នុងរបាររុករកខាងលើ បន្ទាប់មកចុច ***Find My School (ស្វែងរកសាលារបស់ខ្ញុំ)***។




ទំព័រ **Explore** នឹងផ្ទុក។ អានការបដិសេធមិនទទួលខុសត្រូវនៅជ្រុងខាងក្រោមខាងស្តាំនៃអេក្រង់។ បន្ទាប់ពីអានការបដិសេធមិនទទួលខុសត្រូវរួច សូមចុចលើសញ្ញា X ដើម្បីបិទការបដិសេធមិនទទួលខុសត្រូវ។



# ***ការរុករកទូទៅ***

**Explore** មានមុខងារជាច្រើន រួមទាំងផែនទីអន្តរកម្ម របារស្វែងរកអាសយដ្ឋាន
ការចូលប្រើរហ័សទៅកាន់តម្រង និងមុខងារស្វែងរកពាក្យគន្លឹះ
និងការចូលប្រើយ៉ាងងាយស្រួលដើម្បីមើលសាលារៀនណាមួយដែលអ្នកអាចនឹងរក្សាទុក។




បញ្ជីឈ្មោះមណ្ឌលសិក្សាធិការ និងកម្មវិធីសិក្សាបង្ហាញនៅជ្រុងខាងស្តាំនៃអេក្រង់។
បញ្ជីឈ្មោះសាលានេះនឹងកំណត់ជាលំនាំដើមដើម្បីបង្ហាញសាលារៀនតាម លំដាប់អក្ខរក្រម
ប៉ុន្តែអាចតម្រៀបតាម ចម្ងាយ
និងតំបន់ចំណុះ**ក្រោយពី**អាសយដ្ឋានត្រូវបានបញ្ចូលក្នុងកន្លែងបញ្ចូលស្វែងរកអាសយដ្ឋាន។



ដាក់ម៉ៅស៍សំកាំងពីលើសាលារៀនមួយនៅជ្រុងខាងស្តាំនៃអេក្រង់ ដើម្បីមើលទីតាំងសាលារបស់វានៅលើផែនទីអន្តរកម្ម។




ចុចលើសាលារៀន (ក្នុងបញ្ជី ឬនៅលើផែនទី) ដើម្បីបើកផ្ទាំងមួយនៅខាងឆ្វេង ដែលបង្ហាញប្រវត្តិរូបរបស់សាលារៀនដែលបានជ្រើសរើស ប្រវត្តិរូបរបស់សាលារៀន រំលេចព័ត៌មានសំខាន់ៗអំពី សាលារៀន និងរួមបញ្ចូលផ្ទាំងខាងក្រោម៖




- *ព័ត៌មាន* - មានព័ត៌មានទូទៅអំពីសាលារៀន រួមទាំងថ្នាក់ ចំនួនចុះឈ្មោះចូលរៀន ប្រភេទចូលរៀន លេខ ទូរសព្ទ ឈ្មោះនាយកសាលា បណ្តាញ សាលារៀន ប្រភេទសាលា ព័ត៌មានឯកសណ្ឋាន និង លេខ ទូរសារ
- ការសិក្សា/ក្រៅកម្មវិធីសិក្សា- មានព័ត៌មានទាក់ទងនឹងកម្មវិធីសិក្សា និងសកម្មភាពក្រៅកម្មវិធីសិក្សា
- អ្នករៀបចំផែនការ ធ្វើដំណើរ Septa- មានតំណភ្ជាប់ទៅកាន់ គេហទំព័រ Septa ដើម្បីជួយគ្រួសារក្នុងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ
- លក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបាន - មានថ្នាក់ ការវាយតម្លៃ វត្តមាន និងលក្ខណៈវិនិច្ឆ័យនៃសិទ្ធិទទួលបានបន្ថែមណាមួយ ***(ផ្ទាំងនេះបង្ហាញសម្រាប់សាលារៀនដែលផ្អែកលើលក្ខណៈវិនិច្ឆ័យតែប៉ុណ្ណោះ)។***

# ការស្វែងរក សាលារៀនប្រចាំតំបន់ចំណុះ របស់អ្នក

វាយបញ្ចូល អាសយដ្ឋានរបស់អ្នកនៅក្នុងកន្លែងបញ្ចូលស្វែងរកអាសយដ្ឋាន ហើយជ្រើសរើសអាសយដ្ឋានរបស់អ្នកពីបញ្ជីនៃការផ្គូផ្គងដែលអាចមានដែលបង្ហាញនៅក្នុងម៉ឺនុយទម្លាក់។




បញ្ជីឈ្មោះសាលារៀននៅជ្រុងខាងស្តាំនៃអេក្រង់នឹងធ្វើបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិ ដើម្បីបង្ហាញ**សាលារៀនប្រចាំតំបន់ចំណុះ**ដែលភ្ជាប់ជាមួយអាសយដ្ឋាននៅផ្នែកខាងលើនៃបញ្ជី។

- ដោយសារមានសាលារៀនប្រចាំតំបន់ចំណុះច្រើនជាងមួយអាចត្រូវបាន ភ្ជាប់ជាមួយនឹងអាសយដ្ឋាន បញ្ជីឈ្មោះ ក៏នឹងរួមបញ្ចូលកម្រិតថ្នាក់ដែលផ្តល់ជូននៅសាលារៀនប្រចាំតំបន់ចំណុះដើម្បីជួយគ្រួសារយល់ដឹងថាតើសាលាណាផ្តល់ថ្នាក់ទីប៉ុន្មានផងដែរ។



បានធ្វើបច្ចុប្បន្នភាព៖ 08/16/2024

# ***ការច្រោះជម្រើសសាលា***

ចុចប៊ូតុង ***Filter (តម្រង)***
ដើម្បីបង្ហាញជម្រើសតម្រងដែលមាននៅក្នុងម៉ឺនុយនៅលើផ្នែកខាងឆ្វេងនៃអេក្រង់។




ជម្រើសតម្រងខាងក្រោមគឺមាន៖

- ចម្ងាយប្រហាក់ប្រហែល *(ពីអាសយដ្ឋានដែលបានវាយបញ្ចូលក្នុងកន្លែងបញ្ចូលស្វែងរកអាសយដ្ឋាន)*
- ថ្នាក់
- ថ្នាក់ដែលចូលរួមក្នុងការជ្រើសរើសសាលារៀន
- លក្ខណៈវិនិច្ឆ័យនៃសិទ្ធទទួលបាន *(សម្រាប់សាលារៀនផ្អែកលើលក្ខណៈវិនិច្ឆ័យដែលចូលរួមក្នុងការជ្រើសរើសសាលារៀន)*
- តម្រងកម្មវិធី និងអត្តពលិក (*បាទ-ចាស/ទេ សូចនាករសម្រាប់កម្មវិធីផ្អែកលើការអនុវត្តអាជីព និង កម្មវិធីអប់រំបច្ចេកទេស កម្មវិធីដាក់ក្នុងសាលាកម្រិតខ្ពស់ កម្មវិធីមធ្យមសិក្សាទុយភូមិអន្តរជាតិ កម្មវិធីបង្រៀនពីរភាសា អត្តពលកម្ម វគ្គសិក្សាពិជគណិតទី1 នៃអនុវិទ្យាល័យ កម្មវិធីបំប៉នបន្ថែមក្រោយចេញពីសាលា សកម្មភាពកម្មវិធីសិក្សាបន្ថែម)*។
- ការទទួលឲ្យចូលសាលា ប្រភេទ
- បណ្តាញការសិក្សា

តម្រងច្រើនអាចត្រូវបានប្រើដើម្បីបង្រួញលទ្ធផលស្វែងរកសាលារបស់អ្នក។ នៅពេលដែលតម្រងត្រូវបានជ្រើសរើស ផែនទីអន្តរកម្ម និងបញ្ជីឈ្មោះសាលារៀននឹងធ្វើបច្ចុប្បន្នភាពដើម្បីបង្ហាញសាលារៀនដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យតម្រងរបស់អ្នក។

ដើម្បីជម្រះតម្រងដែលបានជ្រើសរើសយ៉ាងរហ័ស សូមចុច ***Clear (ជម្រះ)*** នៅផ្នែកខាងលើនៃម៉ឺនុយ **Filter (តម្រង)**។ ដើម្បីបិទម៉ឺនុយ តម្រង សូមចុចប៊ូតុង ***Filter (តម្រង)***



# ***ស្វែងរកដោយប្រើ ពាក្យ គន្លឹះ***

ចុច ***Keyword (ពាក្យគន្លឹះ)*** ដើម្បីបើកកន្លែងបញ្ចូលស្វែងរកពាក្យគន្លឹះ។ ផែនទី និងបញ្ជីឈ្មោះសាលានឹងធ្វើបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិ ដោយផ្អែកលើពាក្យដែលបានវាយបញ្ចូល។ ការស្វែងរកពាក្យគន្លឹះនឹងបង្ហាញសាលារៀនដែលមានប្រវត្តិរូបរួមបញ្ចូលពាក្យដែលអ្នកបានវាយបញ្ចូល។




# ***ការរក្សាទុកសាលារៀន***

ដើម្បីរក្សាទុកសាលារៀន ឬជម្រើសកម្មវិធី ឬសាលាទៅក្នុងបញ្ជីឈ្មោះសាលាដែលបានរក្សាទុករបស់អ្នក សូមចុចរូបតំណាងទីចំណាំ (មាននៅក្នុងផ្ទាំងប្រវត្តិរូបសាលារៀននៅផ្នែកខាងឆ្វេងនៃអេក្រង់ និងបញ្ជីឈ្មោះសាលានៅខាងស្តា▯)។




បន្ទាប់ពីរក្សាទុកសាលារៀនដំបូងរបស់អ្នកហើយ សារផុសឡើងនឹងបង្ហាញដែលអនុញ្ញាតឱ្យអ្នកដឹងថាអ្នកបានរក្សាទុកសាលាដំបូងរបស់អ្នកហើយ។



បន្តរក្សាទុកសាលារៀន។
មិនមានដែនកំណត់ចំពោះចំនួនសាលារៀនដែលអ្នកអាចរក្សាទុកបាននោះទេ។
ដើម្បីមើលសាលារៀនដែលអ្នកបានរក្សាទុក សូមចុច ***Saved Schools (សាលារៀនដែលបានរក្សាទុក)***។




បញ្ជីឈ្មោះសាលារៀន ដែលបានរក្សាទុករបស់អ្នកនឹង បង្ហាញ។ អ្នកអាចផ្ញើសារ ឬផ្ញើអ៊ីមែលបញ្ជីឈ្មោះរបស់អ្នកដើម្បីចែករំលែកវាជាមួយអ្នកដទៃបាន ដោយ ចុចលើរូបតំណាងនៅខាងឆ្វេងផ្នែកខាងក្រោមនៃបញ្ជីឈ្មោះសាលារៀនដែលបានរក្សាទុក។

- **បញ្ជីឈ្មោះសាលារៀនដែលបានរក្សាទុកនឹងមិនរក្សាទុកជាអចិន្ត្រៃយ៍ទេ។** អ្នកអាចបាត់បង់សាលារៀនដែលអ្នកបានរក្សាទុក ដោយសារការកំណត់កម្មវិធីរុករក ឬបញ្ហាការតភ្ជាប់អ៊ីនធឺណិត។ **យើង សូមណែនាំឱ្យចែករំលែកសាលារៀនដែលអ្នកបានរក្សាទុក ប្រសិនបើអ្នកចង់ធានាថា អ្នកមិនបាត់បង់បញ្ជីឈ្មោះសាលារៀនដែលអ្នកបានរក្សាទុកទៅតាម ពេលវេលា។**



បានធ្វើបច្ចុប្បន្នភាព៖ 08/16/2024

# *ការបញ្ចូលសាលារៀនដែលបានរក្សាទុកទៅក្នុង ពាក្យសុំ របស់អ្នក*

**មុខងារនេះនឹងមាននៅថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2024 វេលាម៉ោង 4:00 ល្ងាច រហូតដល់ថ្ងៃទី 23 ខែតុលា ឆ្នាំ 2024 វេលាម៉ោង 11:59 យប់។**

នៅពេលដែលដំណាក់កាលដាក់ពាក្យសុំជ្រើសរើសសាលារៀន **បើក** សម្រាប់ឆ្នាំសិក្សា 2025-2026 អ្នកដាក់ពាក្យអាចនាំចូលសាលារៀនដែលបានរក្សាទុករបស់ពួកគេដោយផ្ទាល់ទៅក្នុង **ពាក្យសុំដែលមានស្រាប់** របស់ពួកគេ។

ជំហានខាងក្រោមនឹងមាននៅក្នុងដំណាក់កាលនៃការដាក់ពាក្យសុំជ្រើសរើសសាលារៀនតែប៉ុណ្ណោះ។

បើអ្នកដាក់ពាក្យ **មិនបាន** ចូលគណនីប្រព័ន្ធជ្រើសរើសសាលារៀនរបស់ពួកគេរួចហើយនោះទេ ពួកគេនឹងត្រូវចូលទៅក្នុងគណនីរបស់ពួកគេ ដើម្បីនាំចូលជម្រើសសាលារៀនរបស់ពួកគេ។

## ការរំលឹកសំខាន់ៗ

- **កម្មវិធីនឹងអនុញ្ញាតតែការជ្រើសរើសសាលារៀន/កម្មវិធីបានត្រឹមតែប្រាំប៉ុណ្ណោះ - ទោះបីជាគ្រួសារអាចបញ្ចូលសាលារៀន/កម្មវិធីច្រើនជាងប្រាំទៅក្នុងបញ្ជីឈ្មោះសាលារៀនដែលបានរក្សាទុករបស់ពួកគេនៅក្នុងកម្មវិធីរុករកក៏ដោយ។** នេះដោយសារតែ Explore មានគោលបំណងជួយគ្រួសារស្វែងយល់អំពីជម្រើសសាលារៀន ហើយពាក្យស្នើសុំគឺជាកន្លែងកំពូលទាំងប្រាំត្រូវបានបញ្ចូល និងដាក់ចំណាត់ថ្នាក់តាមលំដាប់នៃចំណូលចិត្ត។
  - បើអ្នកដាក់ពាក្យបានព្យាយាមនាំចូលសាលារៀនដែលបានរក្សាទុកច្រើនជាងប្រាំនោះ មានតែសាលារៀនចំនួនប្រាំដំបូងប៉ុណ្ណោះនឹង ត្រូវបានបញ្ចូលទៅក្នុងពាក្យសុំ។
  - លំដាប់នៃសាលារៀនអាចកែតម្រូវបាននៅក្នុង Explore ដោយចុច និងអូសជម្រើសសាលារៀន ដើម្បីតម្រៀបបញ្ជីឈ្មោះសាលារៀនដែលបានរក្សាទុកឡើងវិញ។
- អ្នកប្រើអាចបញ្ចូលបានតែសាលា/កម្មវិធីដែលផ្តល់កម្រិតថ្នាក់ដែលសិស្សកំពុងដាក់ពាក្យសុំ ទៅពេលបញ្ចូលបញ្ជីឈ្មោះសាលារៀនដែលបានរក្សាទុកទៅក្នុងពាក្យសុំរបស់ពួកគេប៉ុណ្ណោះ។ សាលាណាដែលមិនផ្តល់កម្រិតថ្នាក់នឹងមិនត្រូវបានបញ្ចូលទៅក្នុងពាក្យសុំទេ។

## ការនាំចូលជម្រើសសាលារៀនរបស់អ្នក

បន្ទាប់ពីរក្សាទុកជម្រើសសាលារៀន/កម្មវិធីរបស់អ្នកនៅក្នុង **Explore** ហើយ សូមចុច ***Saved Schools (សាលារៀនដែលបានរក្សាទុក)*** ដើម្បីមើលបញ្ជីឈ្មោះសាលារៀនដែលអ្នកបានរក្សាទុក។ បន្ទាប់មកចុច ***Apply Now (ដាក់ពាក្យឥឡូវ)***។



អ្នកប្រើដែលមិនបានចូលទៅក្នុងគណនីប្រព័ន្ធជ្រើសរើសសាលារៀនរបស់ពួកគេទេ ចាំបាច់នឹងត្រូវចូល។

- មាតាបិតានៃសិស្ស School District of Philadelphia បច្ចុប្បន្នគួរតែចុចចូល ជាមួយ PhilaSD ដែលត្រូវ នាំ ទៅកាន់អេក្រង់ចូលតែមួយដងរបស់មណ្ឌលសិក្សាធិការ។
- មាតាបិតាសិស្សដែលមិនមែនជាសិស្សមណ្ឌលសិក្សាធិការគួរតែបញ្ចូលអ៊ីមែល និងពាក្យសម្ងាត់របស់ពួកគេដែលត្រូវបានបង្កើតឡើងនៅពេលពួកគេបង្កើតគណនីរបស់ពួកគេ។




បន្ទាប់ពីចូលហើយ ពួកគេនឹងត្រូវបាននាំទៅកាន់អេក្រង់ដើមរបស់ពួកគេ។ ផ្ទាំងបដានឹងបង្ហាញនៅផ្នែកខាងលើនៃអេក្រង់ដែលនិយាយថា *សាលារៀនដែលបានរក្សាទុករបស់អ្នករួចរាល់ហើយក្នុងការបញ្ចូលទៅទម្រង់បែបបទថ្មីមួយ។*



ចុច ***Resume form (ទម្រង់បែបបទបន្ត)*** ដើម្បីបញ្ចូលជម្រើស
ដែលបានរក្សាទុកទៅពាក្យសុំដែលកំពុងដំណើរការ ឬចុច ***Start form (ចាប់ផ្តើមទម្រង់បែបបទ)***
ដើម្បីបង្កើតពាក្យសុំសម្រាប់សិស្ស។




បន្ទាប់ពីបញ្ចប់ផ្នែកដំបូងនៃពាក្យសុំ *(ព័ត៌មានសិស្ស)* រួចហើយ
វិនដូផុសឡើងនឹងលេចឡើងបន្ទាប់ពីអ្នកចុច ***Next (បន្ទាប់)***
ដើម្បីបន្តទៅផ្នែក *ការជ្រើសរើសសាលារៀន/កម្មវិធី*នៃពាក្យសុំ។
វិនដូផុសឡើងនឹងជូនដំណឹងអ្នកថាសាលារៀនដែលបានរក្សាទុកពីមុនរបស់អ្នកនឹងត្រូវបានបញ្ចូលទៅក្នុងពាក្យសុំ។ ដើម្បីបញ្ចូលសាលារៀន សូមចុច ***Yes, add schools (បាទ/ចាស*** បញ្ចូល ***សាលារៀន)***។




បន្ទាប់មកសាលារៀននឹងបង្ហាញនៅលើពាក្យសុំ។

## សារកំហុស

បើអ្នកព្យាយាមបញ្ចូលសាលារៀន/កម្មវិធីដែល**មិនផ្តល់កម្រិតថ្នាក់ដែលសិស្សកំពុងដាក់ពាក្យសុំទៅនោះទេ** សារព្រមាននឹង លេចឡើង ដោយបញ្ជាក់ថា សាលារៀនទាំងនោះនឹងមិនត្រូវបានបញ្ចូលទៅក្នុងពាក្យសុំនោះទេ។




បើអ្នកព្យាយាមបញ្ចូលសាលារៀន/កម្មវិធីច្រើនជាងប្រាំ នោះសារព្រមាននឹង លេចឡើង ដែលអនុញ្ញាតឱ្យអ្នកដឹងថាមានតែសាលារៀន/កម្មវិធីប្រាំដំបូងប៉ុណ្ណោះក្នុងបញ្ជីឈ្មោះសាលាដែលបានរក្សាទុករបស់អ្នកនឹងត្រូវបានបញ្ចូលទៅក្នុង ពាក្យសុំរបស់អ្នក។




អ្នកដាក់ពាក្យអាចលៃតម្រូវជម្រើសសាលារៀនរបស់ពួកគេនៅក្នុងពាក្យសុំរបស់ពួកគេនៅពេលដែលបើកទទួលពាក្យ។ ការណែនាំបន្ថែមទៀតសម្រាប់ការបង្កើត និងដាក់ពាក្យសុំ អាចរកឃើញនៅលើគេហទំព័រការជ្រើសរើសសាលារៀន (https://www.philasd.org/studentplacement/school-selection/#appprocess) ។